ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ៨៦៩.៧៨៧./គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦

# **គោរពជូន**

## **ឯកឧត្តមអភិបាលរាជធានីភ្នំពេញ ខេត្តក្រចេះ ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី**

**<u>កម្មវត្ថុ</u>** ៖ ការគាំទ្រមូលនិធិឃុំ សង្កាត់ដោយ UNICEF សម្រាប់ការលើកកម្ពស់សេវាសង្គមឆ្នាំ២០១៧។

**<u>យោង</u>** ៖ កិច្ចព្រមព្រៀងឆ្នាំ២០១៦-២០១៧ រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងកម្មវិធីសិទ្ធិកុមារនៃអង្គការ UNICEF ។

សេចក្ដីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ក្នុងគោលបំណងរួមចំណែកលើកកម្ពស់សេវាសង្គមនៅថ្នាក់មូលដ្ឋាន លេខាធិការដ្ឋាន គ.ជ.អ.ប. សូមផ្ដល់ជូនព័ត៌មានជាបឋមអំពីកញ្ចប់មូលនិធិឆ្នាំ២០១៧ របស់កម្មវិធីសិទ្ធិកុមារនៃអង្គការ UNICEF សម្រាប់គាំទ្រមូលនិធិឃុំ សង្កាត់ផ្នែកសេវាសង្គមដែលបានវិភាជសម្រាប់ឃុំ សង្កាត់គោលដៅនីមួយៗ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ឃុំ សង្កាត់ទាំងនោះអាចបញ្ចូលតួលេខនៃមូលនិធិនេះទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ២០១៧ របស់ខ្លួនឱ្យបានទាន់ពេលវេលា។ នៅពេលមូលនិធិគាំទ្រនេះត្រូវបានផ្ទេរពីថ្នាក់ជាតិ ចំនួនមូលនិធិសរុបតាមឃុំ សង្កាត់គោលដៅនីមួយៗអាចមានការប្រែប្រួលបន្តិចបន្តួច អាស្រ័យលើអត្រាប្ដូរប្រាក់ជាក់ស្ដែងក្នុងខែនីមួយៗ ដូច្នេះ ឃុំ សង្កាត់គោលដៅនីមួយៗនឹងត្រូវធ្វើការកែសម្រួលគម្រោងថវិកាឆ្នាំ២០១៧ របស់ខ្លួន ស្របតាមចំនួនមូលនិធិជាក់ស្ដែងដែលបានទទួល។

បន្ទាប់ពីទទួលបាននូវព័ត៌មានជាបឋមអំពីកញ្ចប់មូលនិធិសម្រាប់ឆ្នាំ២០១៧ ឃុំ សង្កាត់គោលដៅនីមួយៗត្រូវរៀបចំបញ្ចូលក្នុងគម្រោងថវិកាឆ្នាំ២០១៧ របស់ខ្លួនក្នុងជំពូក ៦២ សម្រាប់សកម្មភាពសេវាសង្គមនានា និងក្នុងអនុគណនី ៦១០៩៣ សម្រាប់ប្រាក់ឧបត្ថម្ភគ្រូមត្តេយ្យសហគមន៍។ ចំពោះការប្រើប្រាស់មូលនិធិនេះ គឺត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីនានាសម្រាប់សេវាសង្គមដែលបានអនុវត្តកន្លងមក។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងណែនាំដល់មេឃុំ ចៅសង្កាត់នៃឃុំ សង្កាត់គោលដៅដើម្បីបញ្ចូលមូលនិធិនេះ ក្នុងគម្រោងថវិកាឆ្នាំ២០១៧ របស់ខ្លួនឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**ជ.ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**<u>ចម្លងជូន៖</u>**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃរាជធានី ខេត្តគោលដៅទាំង៣
- រតនាគារនៃរាជធានី ខេត្តគោលដៅទាំង៣
- ឯកសារ-កាលប្បវត្តិ